# ខ្លឹមសារសង្ខេប

សាលដីកាព្រហ្មទណ្ឌលេខ៣១ (១៩កុម្ភៈឆ្នាំ ២០១៤) តុលាការកំពូល

**ពាក្យគន្លឹះ៖** រំលោភសេពសន្ថវៈ និងប៉ុនប៉ងរំលោភសេពសន្ថវៈ ការប្តូរប្រភេទបទល្មើស អនីតិជន អាជ្ញាយុកាលនៃការចោទប្រកាន់

## ១. អង្គហេតុនិងប្រវត្តិនីតិវិធី

ជនជាប់ចោទ ជាឪពុកចុង ត្រូវបានចោទថាប៉ុនប៉ងរំលោភកូនស្រីចុង ដែលពេលនោះមានអាយុ ១០ឆ្នាំ។ អង្គហេតុ (១៥ខែកញ្ញា ឆ្នាំ២០០៧) បង្ហាញថាគាត់បានព្យាយាម (ទាញដៃកូនស្រីឲ្យទៅដេកជាមួយ) ដឹងលឺដល់អ៊ំស្រី ក៏នាំឲ្យមានបណ្តឹងបរិហារ ឃាត់ខ្លួន និងផ្តន្ទាទោស។ ក្នុងដំណើរការក្តី មានធ្លាយព័ត៌មានថា គាត់ធ្លាប់រួមភេទជាច្រើនដងកន្លងមក ជាមួយកូនចុង ទោះបីមិនច្បាស់ថា មានការព្រមព្រៀងឬគ្មាន។

សាលក្រមសាលាដំបូងខេត្តក្រចេះលេខ៦២ក (កញ្ញា២០០៩) សម្រេចរួចខ្លួនពីបទចោទប្រកាន់៖ ប៉ុនប៉ងរំលោភសេពសន្ថវៈ។ លោកព្រះរាជអាជ្ញារង បានប្តឹងឧទ្ធរណ៍ឆ្នាំ២០០៩។ សាលាឧទ្ធរណ៍ តាមសាលដីកាលេខ១៥ក្រIII (មីនា ២០១១) សម្រេចបដិសេធសាលក្រមលេខ៦២ និងផ្តន្ទាទោស១០ឆ្នាំពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ បានប្តឹងសាទុក្ខ និងអះអាងស្នើឲ្យប្តូរទៅជាបទរំលោភសេពសន្ថវៈ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលស្នើឲ្យ ប្តូរទៅជាបទរំលោភសេពសន្ថវៈ។ តុលាការកំពូល បានបើកសវនាការលើកទីមួយខែមករាឆ្នាំ២០១៤ ដោយបដិសេធខ្លះ និងបង្វិលទៅសាលាឧទ្ធរណ៍ឲ្យជម្រះឡើងវិញនូវចំណុចទី៣នៃសាលដីកាលេខ១៥ (ដាក់ទោស១០ឆ្នាំពីបទប៉ុនប៉ុងរំលោភសេពសន្ថវៈ)។

## ២. សម្គាល់ហេតុឬការយល់ឃើញ

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍បានសម្រេចបដិសេធសាលក្រម...ជាការត្រឹមត្រូវហើយ ...ប៉ុន្តែការដែលយកចិត្តទុកដាក់តែទៅលើអំពើល្មើសច្បាប់ចុងក្រោយ...*ដូច្នេះអំពើ ដែលបានប្រព្រឹត្តដោយជនជាប់ចោទ ជាច្រើនលើកច្រើនសារកន្លងមកនេះ មិនមែនជាអំពើស្របច្បាប់ទេ សុទ្ធតែជាអំពើប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌ មិនគប្បីទុកចោលឲ្យបទល្មើសព្រហ្មទណ្ឌ ដែលបានកើតឡើងហើយស្ថិតនៅក្រៅអានុភាពច្បាប់នោះទេ ដរាបណាមិនទាន់ផុតអាជ្ញាយុកាលនៅឡើយ*។

...ចាំបាច់ត្រូវស៊ើបសួរបន្ថែម ដើម្បីផ្ទៀងផ្ទាត់ ៖ ១. ពេលវេលាកើតហេតុ រំលោភបំពានផ្លូវភេទលើកដំបូងនៅពេលណា? ពេលនោះ កំពុងស្ថិតនៅក្រោមអានុភាពច្បាប់ព្រហ្មទណ្ឌណាមួយដែលនៅជាធរមាន ហើយអំពើបន្តបន្ទាប់មកទៀត ស្ថិតនៅក្រោមអានុភាពច្បាប់ព្រហ្មទណ្ឌណាទៀត។ ក្រមព្រហ្មទណ្ឌ ពុំមានអានុភាពប្រតិសកម្មទេ។

## ៣. សេចក្តីសម្រេច

- តុលាការកំពូលសម្រេចទទួលយកបណ្តឹងសាទុក្ខ..

-បដិសេធចោលជាអសារបង់ ត្រង់សេចក្តីសម្រេចចំណុចទី៣ និងបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍វិញ ដើម្បីជំនុំជម្រះជាថ្មីចំណុចទី៣នេះ។

## ៤. ខ្លឹមសារដកស្រង់ឬយោបល់

វាមានភាពមិនច្បាស់លាស់រវាងបទរំលោភសេពសន្ថវៈ និងការប៉ុនប៉ងរំលោភសេពសន្ថវៈ។ នេះហើយ ទើបធ្វើឲ្យមានការខ្វែងយោបល់រវាងចៅក្រម និងព្រះរាជអាជ្ញា។ យុត្តិសាស្ត្រតុលាការប្រទេសកុំមុនឡ បានអនុម័តនូវលក្ខណវិនិច្ឆ័យមួយ គឺភាពកៀកកិត (approximate test) ដែលសំដៅថាសកម្មភាពល្មើស កៀកកិតនឹងការបញ្ចប់បទល្មើស។ ក្នុងករណីប៉ុនប៉ងរំលោភសេពសន្ថវៈ វាអាចថាជនសង្ស័យ ហែកអាវជនរងគ្រោះ ចាប់ផ្ដួល....។

ដើម្បីសន្តិសុខ និងសណ្ដាប់ធ្នាប់ ទង្វើល្មើសត្រូវតែរងនូវការស៊ើបអង្កេត ប្រសិនបើអាជ្ញាយុកាលនៃការចោទប្រកាន់មិនទាន់ហួសពេល។ នេះជាពិសេស គឺករណីបទល្មើសដែលកើតមានចំពោះអនីតិជន។

**សាលដីកាទាំងមូលមាននៅក្នុង**

http://www.measboralaws.com/images/pdf/verdict/a8cbcc56865cddabc7c27f632d9efd52.pdf